URATA (CAMBODIA) CO.,LTD.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា.....................................

កិច្ចសន្យានេះត្រូវបានបង្កើតឡើងនៅថ្ងៃទី ........... ខែ ............ ឆ្នាំ............

## រវាង

ក្រុមហ៊ុន URATA（CAMBODIA）CO.,LTD.
អ្នកតំណាង៖ HOKURA KATSUYOSHI
មានអាជ្ញាប័ណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ កម្រិត១ លេខ០០០២ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២
អាសយដ្ឋានបច្ចុប្បន្ន: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម នឹងសំណង់, ជាន់ទី៥ បន្ទប់លេខ៥១៥, ឡូតិ៍លេខ#2005, ផ្លូវ ៣០៧, សង្កាត់ ឃ្មួញ, ខណ្ឌ សែនសុខ, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា
លេខទូរស័ព្ទ (+៨៥៥) ២៣ ៩០២ ១១៥
(ហៅកាត់ថាជា **ភាគី "ក"**)

លោក/លោកស្រី......................................................
តំណាងដោយ................................................
ជាម្ចាស់សំណង់កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ.............................. អាសយដ្ឋានបច្ចុប្បន្ន ផ្ទះ/អគារលេខ..............................ជាន់ទី..........................ផ្លូវ.................ភូមិ.................ឃុំ/សង្កាត់..................ក្រុង/ស្រុក/ខណ្ឌ............................
លេខទូរស័ព្ទ.......................................
(ហៅកាត់ថាជា **ភាគី "ខ"**)

## បុព្វកថា

**ដោយហេតុថា** ភាគី "ខ" មានបំណងជួលភាគី "ក" ធ្វើ«ការងារត្រួតពិនិត្យ និងបញ្ជាក់...............................»សម្រាប់អគារដូចមានចែងក្នុងចំណុច១.១ ខាងក្រោម ហើយភាគី "ក" បានយល់ព្រមទទួលយកការងារនោះ។

**ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖**

## ប្រការ១ ទីតាំង ទំហំ និងប្រភេទការងារ

១.១ ភាគី "ខ" យល់ព្រមប្រគល់ គម្រោងប្លង់ ឯកសារបច្ចេកទេស និងឯកសារផ្សេងទៀតទាក់ទងនឹងសំណង់ ដែលចាំបាច់សម្រាប់«ការងារ.........................» (តទៅនេះហៅថា "**ឯកសារចាំបាច់**") ទៅឲ្យភាគី "ក"។ ភាគី "ក" អាចស្នើសុំឱ្យភាគី "ខ" ផ្តល់ឯកសារបន្ថែម ដើម្បីបង្កើនសុក្រឹតភាពការងារ ហើយបន្ទាប់ពីទទួលបានឯកសារបច្ចេកទេសពីភាគី "ខ" ភាគី "ក" ត្រូវចេញលិខិតប្រគល់ទទួលឯកសារដែលមានកាលបរិច្ឆេទនិងហត្ថលេខារបស់ភាគីទាំងពីរ តាមទម្រង់ដែលបានកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (តទៅនេះហៅថា "MLMUPC")។

ភាគី "ខ" ត្រូវប្រគល់ឯកសារចាំបាច់ដែលត្រូវបានធ្វើឡើងដោយអ្នកសិក្សាគម្រោងប្លង់/ក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងត្រូវមានព័ត៌មានដូចខាងក្រោម៖

អ្នកសិក្សាគម្រោងប្លង់/ឈ្មោះក្រុមហ៊ុនសិក្សាគម្រោងប្លង់

លោក/លោកស្រី.......................................................តំណាងឲ្យ.......................................................
ចុះថ្ងៃទី..............ខែ.............ឆ្នាំ............ដីឡូត៍លេខ.................ផ្លូវ...............ភូមិ.....................ឃុំ/សង្កាត់
.........................ក្រុង/ស្រុក/ខណ្ឌ...........................រាជធានី/ខេត្ត............................................
លេខទូរស័ព្ទ................................................
ដើម្បីឱ្យ ភាគី "ក" អនុវត្តការងារ«..........................................................» (តទៅនេះហៅថា "ការងារ")។

១.២ ភាគី "ក" ត្រូវធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ និងត្រូវចេញលិខិតបញ្ជាក់អនុលោមភាពដោយបញ្ជាក់ច្បាស់លាស់ពីអនុលោមភាពនៃគម្រោងប្លង់ដល់ភាគី "ខ" តាមទម្រង់ដែលតម្រូវនិងទទួលស្គាល់ដោយMLMUPC។ របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ និងលិខិតបញ្ជាក់អនុលោមភាពគម្រោងប្លង់ ត្រូវធ្វើឡើងយ៉ាងតិចចំនួន៥ច្បាប់ និងត្រូវប្រគល់ជូនភាគី "ខ" ចំនួន៣ច្បាប់ ប្រគល់ជូនអ្នកសិក្សាគម្រោងប្លង់ ចំនួន១ច្បាប់ និងរក្សាទុកនៅភាគី "ក" ចំនួន១ច្បាប់។

១.៣ ប្រសិនបើភាគី "ក" បានពិនិត្យគម្រោងប្លង់ ឯកសារចាំបាច់ ហើយរកឃើញថាគម្រោងប្លង់មានចំណុចខ្វះចន្លោះ ឬមិនត្រឹមត្រូវ ឬមិនអនុលោមតាមបទប្បញ្ញត្តិនៃបច្ចេកទេសសំណង់ ភាគី "ក" ត្រូវចេញលិខិតជូនដំណឹងអំពីភាពមិនត្រឹមត្រូវជូនភាគី "ខ" ដែលមានសរសេរអំពីចំណុចខ្វះចន្លោះ ភាពមិនត្រឹមត្រូវ និងមិនអនុលោមភាព និងកំណត់រយៈពេលសម្រាប់កែតម្រូវ (តទៅនេះហៅថា "រយៈពេលកែតម្រូវ") តាមទម្រង់ដែលតម្រូវនិងទទួលស្គាល់ដោយ MLMUPC។ ភាគីទាំងពីរយល់ព្រមថារយៈពេលកែតម្រូវមិនត្រូវរាប់បញ្ចូលក្នុងរយៈពេលធ្វើការងារនៃកិច្ចព្រមព្រៀងនេះទេ។ ប្រសិនបើមិនមានការកែតម្រូវនូវចំណុចខ្វះចន្លោះ ភាពមិនត្រឹមត្រូវ និងមិនអនុលោមភាពបន្ទាប់ពីរយៈពេលកែតម្រូវបានកន្លងផុតទៅទេ ភាគី "ក" អាចចេញរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ដែលមានសរសេរអំពីចំណុចខ្វះខាត ភាពមិនត្រឹមត្រូវ និងមិនអនុលោមភាព។

 ហត្ថលេខា.................... ហត្ថលេខា..................

១.៤ ប្រសិនបើភាគី "ក" បានពិនិត្យគម្រោងប្លង់ និងឯកសារចាំបាច់ ហើយរកឃើញថាមានភាពមិនអនុលោមត្រូវចេញរបាយការណ៍អំពីចំណុចខ្វះចន្លោះ ។ ប្រសិនបើការកែតម្រូវមិនត្រូវបានធ្វើឡើងក្នុងកំឡុងពេលរាយការណ៍នៃការកែតម្រូវបន្ទាប់ពី រយៈពេលដែលមានប្រសិទ្ធភាព ភាគី "ក" ត្រូវអនុវត្តតាមនីតិវិធីស្របតាមចំណុច 1.3 ខាងលើ។

## ប្រការ២ តម្លៃ កាលបរិច្ឆេទ និងរបៀបនៃការទូទាត់

២.១ តម្លៃសេវាក្នុងកិច្ចសន្យា

ភាគីទាំងពីរបានព្រមព្រៀងលើតម្លៃសេវាតាមចំនួនដូចខាងក្រោម៖

...............................ដុល្លារ (រួមបញ្ចូល អ.ត.ប.........................ដុល្លារ)

(សរសេរជាអក្សរ)....................................................................

២.២ រយៈពេលនៃការងារ

- រយៈពេលនៃការងារត្រួតពិនិត្យ និងបញ្ជាក់: ចំនួន............ថ្ងៃ គិតចាប់ពីថ្ងៃទី.........ខែ..........ឆ្នាំ.......... រហូតដល់ ថ្ងៃទី.......ខែ.........ឆ្នាំ.......

* កាលបរិច្ឆេទចាប់ផ្តើមនៃការងារត្រួតពិនិត្យ និងបញ្ជាក់: នៅថ្ងៃដែលទទួលបានការទូទាត់ប្រាក់លើតម្លៃសេវាលើកទី១ ពេលចុះកិច្ចសន្យា។
* អំឡុងពេលផ្អាកការងារ មិនត្រូវបានរាប់បញ្ចូលក្នុងរយៈពេលនៃការងារត្រួតពិនិត្យ និងបញ្ជាក់ដូចមានចែងក្នុងប្រការ៥ ចំណុច(៥)ទេ។

២.៣ របៀបនៃការទូទាត់

ភាគីទាំងពីរបានព្រមព្រៀងទូទាត់លើតម្លៃសេវាជា..................ដំណាក់កាលដូចខាងក្រោម៖

- ដំណាក់កាលទី១៖ តម្លៃសេវានៅពេលចុះកិច្ចសន្យា
  ......................................ដុល្លារ (រួមបញ្ចូលអ.ត.ប.........................ដុល្លារ)
  (សរសេរជាអក្សរ)....................................................................
- ដំណាក់កាលទី២៖ ចំនួនទឹកប្រាក់ដែលនៅសល់ ត្រូវទូទាត់នៅពេលទទួលបានរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ និងលិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ ឬរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ដែលមានសរសេរអំពីចំណុចខ្វះខាត ភាពមិនត្រឹមត្រូវ និងមិនអនុលោមភាព។
  ......................................ដុល្លារ (រួមបញ្ចូលអ.ត.ប.........................ដុល្លារ)
  (សរសេរជាអក្សរ)....................................................................

 ហត្ថលេខា.................... ហត្ថលេខា.................

២.៤ ព័ត៌មាននៃការទូទាត់ប្រាក់

- ឈ្មោះធនាគារ: ACLDA BANK
- ឈ្មោះគណនី: URATA（CAMBODIA）CO.,LTD INSPECTION
- លេខគណនី: 0001-04311511-32

## ប្រការ៣ ភាតព្វកិច្ចរបស់ភាគី "ក"

ភាគី "ក" ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

៣.១ គោរពនិងអនុវត្តតាមបទប្បញ្ញត្តិរៀបចំដែនដី និងនគរូបនីយកម្ម បទប្បញ្ញត្តិបច្ចេកទេសសំណង់ ស្តង់ដារកម្ពុជា បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំបច្ចេកទេស

៣.២ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបញ្ហាទាំងឡាយដែលទំនាក់ទំនងហេតុនិងផលត្រូវបានទទួលស្គាល់តាមក្រមរដ្ឋប្បវេណីក្នុងចំណោមរាល់បញ្ហាធ្ងន់ធ្ងរដែលកើតឡើងទាក់ទងនឹងការអនុវត្តវិជ្ជាជីវៈ និងការប្រកបអាជីវកម្មរបស់ខ្លួនដែលបណ្តាលមកពីកំហុសរបស់ខ្លួន ។

៣.៣ ធានាអនុវត្តការងារតាមពេលវេលាកំណត់ក្នុងលក្ខខណ្ឌដែលភាគី"ខ" អនុវត្តកាតព្វកិច្ចរបស់ខ្លួន។

៣.៤ អនុវត្តការងាររបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌វិជ្ជាជីវៈ។

## ប្រការ៤ ភាតព្វកិច្ចរបស់ភាគី "ខ"

ភាគី "ខ" ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

៤.១ ប្រគល់គម្រោងប្លង់និងឯកសារបច្ចេកទេសពាក់ព័ន្ធ សម្រាប់ធ្វើការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ជូនទៅភាគី"ក"។

៤.២ ធានាការទូទាត់តម្លៃសេវាជូនភាគី"ក" តាមពេលវេលាកំណត់នៃដំណាក់កាលនីមួយៗ និងមិនបង្កការលំបាកដល់ភាគី"ក" ក្នុងការទទួលប្រាក់ទូទាត់។

៤.៣ ប្រសិនបើទទួលបានការជូនដំណឹងអំពីចំណុចមិនអនុលោមភាពដែលមានចែងក្នុងចំណុច១.៣ខាងលើ ត្រូវចូលរួមសហការជាមួយអ្នកសិក្សាគម្រោងប្លង់/ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដើម្បីកែតម្រូវរាល់ចំណុចខ្វះចន្លោះ ភាពមិនត្រឹមត្រូវ ចំណុចមិនអនុលោមភាព ក្នុងរយៈពេលកែតម្រូវ។

## ប្រការ៥ លក្ខខណ្ឌក្នុងការកែប្រែនិងការរំលាយកិច្ចសន្យា និងការផ្អាកការងារ

៥.១ ភាគីនីមួយៗមានសិទ្ធិស្នើសុំកែប្រែលក្ខខណ្ឌនៃកិច្ចសន្យាបាន ប៉ុន្តែភាគីទាំងពីរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងមានការយល់ព្រមពីភាគីទាំងពីរ ហើយរាល់ការកែប្រែ ឬបន្ថែមលក្ខខណ្ឌនៃកិច្ចសន្យាត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

៥.២ ភាគីទាំងពីមានសិទ្ធិក្នុងការបញ្ចប់កិច្ចសន្យាតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេល ៣០ថ្ងៃទៅភាគីម្ខាងទៀត ហើយកិច្ចសន្យានឹងត្រូវបញ្ចប់តាមការព្រមព្រៀងជាលាយលក្ខណ៍អក្សរ។

៥.៣ ភាគីនីមួយៗមានសិទ្ធិស្នើសុំបញ្ចប់កិច្ចសន្យានេះ ដោយសារការខកខាននៃការអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀត ដោយត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមានបញ្ជាក់អំពីមូលហេតុ។

៥.៤ ភាគី "ក" អាចលុបចោលកិច្ចសន្យា និងអាចផ្អាកការងារត្រួតពិនិត្យ និងបញ្ជាក់នៅក្នុងករណីដូចខាងក្រោមបាន ហើយសិទ្ធិទាមទារដែលកើតឡើងត្រូវមានបន្ត ដោយឡែកតម្លៃសេវាក្នុងកិច្ចសន្យាដែលត្រូវបានទូទាត់រួចរាល់មិនត្រូវបានបង្វិលសងឡើយ។ ម្យ៉ាងទៀត ប្រសិនបើភាគី "ក" ទទួលរងការខូចខាតដោយសារមូលហេតុដូចក្នុងករណីដែលបានកំណត់ខាងក្រោម ភាគី "ក" អាចទាមទារសំណងការខូចខាតពី ភាគី "ខ"បាន។

(១) ប្រសិនបើការទូទាត់ប្រាក់ក្នុងដំណាក់កាលទី១ និងដំណាក់កាល២ លើស៧ថ្ងៃនៃថ្ងៃធ្វើការ (កិច្ចសន្យានឹងត្រូវរំលាយ)

(២) ប្រសិនបើការងារសាងសង់ត្រូវបានចាប់ផ្តើមមុនពេលបញ្ចប់ការងារត្រួតពិនិត្យ និងបញ្ជាក់ (កិច្ចសន្យានឹងត្រូវរំលាយ)

(៣) ប្រសិនបើមានការក្លែងបន្លំនូវឯកសារដែលបានផ្តល់មក និងគម្រោងប្លង់ (កិច្ចសន្យានឹងត្រូវរំលាយ)។

## ប្រការ៦ ករណីប្រធានសក្តិ

៦.១ ប្រសិនបើមិនអាចបន្តកិច្ចសន្យាទៀតបាន ដោយសារគ្រោះធម្មជាតិ ជម្ងឺឆ្លងរាតត្បាត បទប្បញ្ញត្តិឬការណែនាំរបស់រដ្ឋាភិបាល ព្រឹត្តិការណ៍ផ្សេងទៀតដោយសកម្មភាពមនុស្ស (តទៅនេះហៅថា "ប្រធានសក្តិ") ដែលមិនអាចសន្មតថាកើតឡើងដោយសារ ភាគី "ក" ឬ ភាគី "ខ" គូភាគីអាចបញ្ចប់កិច្ចសន្យានេះតាមការព្រមព្រៀងបាន។

៦.២ ភាគីទាំងពីរមិនអាចទាមទារសំណងចំពោះការខូចខាតដែលកើតមានឡើង ក្នុងករណីភាគីម្ខាងទៀតមិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយករណីប្រធានសក្តិបានឡើយ។

## ប្រការ៧ ការពន្យារពេល ការពិន័យ

៧.១ ប្រសិនបើការងារត្រួតពិនិត្យ និងបញ្ជាក់ មិនអាចបញ្ចប់ក្នុងរយៈពេលដែលកំណត់ក្នុងកិច្ចសន្យាដោយសារហេតុផលដែលជាទំនួលខុសត្រូវរបស់ភាគី "ក" ភាគី "ខ" អាចទាមទារប្រាក់ពិន័យគុណនឹង ៥ ភាគ ១០,០០០នៃតម្លៃសេវាក្នុងកិច្ចសន្យាក្នុង១ថ្ងៃ។

## ប្រការ៨ ការដោះស្រាយវិវាទ និងការប្តឹងតវ៉ា

៨.១ ករណីមានវិវាទកើតមានឡើងទាក់ទងនឹងកិច្ចសន្យានេះ ភាគីទាំងពីរត្រូវស្វែងរកដំណោះស្រាយដោយសន្តិវិធីជាមុន តាមរយៈការពិភាក្សា ការសម្រុះសម្រួល និងវិធីសាស្ត្រផ្សេងទៀត

៨.២ ភាគីទាំងពីរអាចធ្វើសំណើរទៅគណៈកម្មាធិការដោះស្រាយវិវាទសំណង់ ដើម្បីសម្រុះសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យានេះមុនប្តឹងទៅតុលាការ

៨.៣ ករណីភាគីទាំងពីរពុំអាចព្រមព្រៀងគ្នាដើម្បីបញ្ចប់វិវាទតាមរយៈការសម្រុះសម្រួលរបស់គណៈកម្មាធិការដោះស្រាយវិវាទសំណង់ ភាគីទាំងពីរមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីច្បាប់ជាធរមាន។

**ប្រការ៩ ការគោរពច្បាប់**

កិច្ចសន្យានេះ មានប្រសិទ្ធិភាពអនុវត្តក្រោមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវធ្វើឡើងជាភាសាខ្មែរ។

កិច្ចសន្យានេះត្រូវបានធ្វើឡើង២ច្បាប់ មានខ្លឹមសារនិងតម្លៃដូចគ្នា ដោយរក្សាទុកនៅភាគី "ក" ចំនួន១ច្បាប់ ភាគី "ខ" ចំនួន១ច្បាប់។ ភាគីទាំងពីរបានអាន និងយល់ច្បាស់អំពីខ្លឹមសារនៃប្រការនីមួយៗនៃកិច្ចសន្យានេះ និងយល់ព្រមផ្តិតស្នាមមេដៃស្តាំ ឬចុះហត្ថលេខា ដើម្បីបញ្ជាក់ពីការយល់ព្រមនិងការទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

| **ភាគី "ក"** | **ភាគី "ខ"** |
|---|---|
| URATA（CAMBODIA）CO.,LTD. | |
| ឈ្មោះ៖ HOKURA KATSUYOSHI | ឈ្មោះ៖....................................... |
| ហត្ថលេខា៖ | ហត្ថលេខា៖ |
| លេខទូរស័ព្ទ៖ (+៨៥៥) ២៣ ៩០២ ១១៥ | លេខទូរស័ព្ទ៖................................. |

***កំណត់សម្គាល់៖*** *គូភាគីនៃកិច្ចសន្យាអាចព្រមព្រៀងបន្ថែមខផ្សេងៗនៃកិច្ចសន្យា ប៉ុន្តែមិនអាចចែងខទាំងឡាយដែលផ្ទុយពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធឡើយ។*